មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ការវិភាគ របស់ ម.ស.ម.ក លើសេចក្ដីព្រាងច្បាប់លើកទី៤ ស្ដីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម

ការវិភាគនេះត្រូវបានតាក់តែងឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យ ដែលធ្វើការលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) ។ នេះជាការវិភាគទៅលើសេចក្ដីព្រាងច្បាប់លើកទី៤ស្ដីពី *"សមាគម និងអង្គការមិនមែនរដ្ឋាភិបាល"* និងផ្ដោតទៅលើចំណុចដូចខាងក្រោម ៖

១. ការផ្លាស់ប្ដូរសំខាន់ៗធៀបទៅនឹងសេចក្ដីព្រាងច្បាប់លើកទីបី
២. ការព្រួយបារម្ភចម្បងៗចំនួន បី របស់ ម.ស.ម.ក និង
៣. សេចក្ដីសន្និដ្ឋាន

## ១) ការផ្លាស់ប្ដូរសំខាន់ៗ

រវាងសេចក្ដីព្រាងច្បាប់លើកទីបី និងលើកទីបួន យើងឃើញថាមានការផ្លាស់ប្ដូរសំខាន់ៗមួយចំនួន។ គោលបំណងនៃផ្នែកនេះ គឺមិនមែនធ្វើការវិភាគមួយមាត្រាម្ដងៗ នៃសេចក្ដីព្រាងច្បាប់ថ្មីនោះទេ ប៉ុន្តែគឺដើម្បីសង្កត់ធ្ងន់លើចំណុចការផ្លាស់ប្ដូរសំខាន់ៗមួយចំនួន ដែលនឹងលើកមកពិភាក្សាតាមលំដាប់នៃមាត្រាក្នុងសេចក្ដីព្រាងច្បាប់នេះ។ មាត្រាជាច្រើននៅក្នុងសេចក្ដីព្រាងច្បាប់លើកទីបី ត្រូវបានលុបចោល ហើយការយកចិត្តទុកដាក់នឹងត្រូវផ្ដោតទៅលើតែមាត្រាទាំងឡាយណាដែលមានសារៈសំខាន់ប៉ុណ្ណោះ។ ការផ្លាស់ប្ដូរផ្សេងៗដែល ម.ស.ម.ក យល់ថាមិនសូវសំខាន់ ដោយសារតែមាត្រាទាំងនោះមានការកែលម្អ ឬក៏ត្រូវបានរៀបចំសាជាថ្មី ឬកែសម្រួលឃ្លា នឹងមិនត្រូវបានពិភាក្សាក្នុងការវិភាគនេះទេ។ មាត្រាទាំងអស់ក្នុងការវិភាគនេះ គឺយោងទៅតាមការដាក់លេខរៀងក្នុងសេចក្ដីព្រាងច្បាប់លើកទីបួន លើកលែងតែមានការបញ្ជាក់ផ្សេងពីនោះ។

- **គោលបំណង (មាត្រា១)** ៖ មានការចែងផ្ដោតសំខាន់បានផ្លាស់ប្ដូរពីការចុះបញ្ជីរបស់អង្គការមិនមែនរដ្ឋាភិបាល និងសមាគម មកជាភាសាដែលមានភាពជាវិជ្ជមានចំពោះសង្គមស៊ីវិល។ មាត្រា១ បានចែងអំពី *"ការពារសិទ្ធិសេរីភាព និងលើកកម្ពស់ចលនាបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលរបស់ប្រជាពលរដ្ឋខ្មែរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងការពារផលប្រយោជន៍សាធារណៈ"*។ ក៏ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) នៅបង្ហាញយ៉ាងច្បាស់ពីបំណងក្នុងការគ្រប់គ្រងសង្គមស៊ីវិល ដោយសារតែគោលបំណងនៃច្បាប់

នេះក៏បានបញ្ជាក់បន្ថែមទៀតថាដើម្បី "*លើកពង្រឹងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាលជាមួយរាជរដ្ឋាភិបាលកម្ពុជា*" ។

- **គោលបំណង (មាត្រា២)** ៖ ភាសាដែលប្រើប្រាស់ត្រូវបានបំព្រួញ ក្នុងគោលដៅបញ្ជាក់ឲ្យច្បាស់ពីការបង្កើតភាពស្របច្បាប់របស់សមាគម និងអង្គការជាជាងលើប្រយោជន៍សាធារណៈ និងសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការបង្កើតអង្គការស្របច្បាប់មួយ (ទោះបីជាគោលបំណងមួយនេះ ត្រូវបានលើកយកមកនិយាយក្នុងមាត្រា១ក៏ដោយ)។ ដូច្នេះ គ្មានការចែកឲ្យដាច់គ្នាក្នុងបរិបទនេះ រវាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស លើកលែងតែចំណុចមួយដែលយោងទៅលើ "គម្រោងជំនួយ" (សូមអានការពិភាក្សាក្នុងផ្នែក ២(១) ខាងក្រោម) ។ នៅតែមានការសង្កត់ធ្ងន់មកលើកិច្ចសហប្រតិបត្តិការរវាង រដ្ឋាភិបាល (អាជ្ញាធរសាធារណៈ) និងសង្គមស៊ីវិល។
- **វិសាលភាព (មាត្រា៣)** ៖ វិសាលភាពនៃច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ក្នុងសេចក្តីព្រាងលើកនេះបានពង្រីកដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ "*ដែលធ្វើសកម្មភាព*" នៅកម្ពុជា ជាជាងគ្របដណ្តប់មកលើតែអង្គការ ឬសមាគមចុះបញ្ជីតាមច្បាប់នេះ។ នេះគឺជាវិសោធនកម្មដ៏សំខាន់មួយ យោងតាមបទប្បញ្ញត្តិនេះ ប្រសិនបើសមាគម ឬអង្គការសម្រេចចិត្តមិនចុះបញ្ជី សមាគម ឬអង្គការទាំងនេះនឹងមិនអាចគេចផុតពីការអនុវត្តន៍ច្បាប់នេះបានទេ ដែលមើលទៅហាក់ដូចជាធ្វើឲ្យការធ្វើវិសោធនកម្មលើបទប្បញ្ញត្តិតម្រូវការចុះបញ្ជីហាក់ដូចជាគ្មានន័យ ( សូមអានខាងក្រោម) ។
- **ការទទួលស្គាល់សមាគមបរទេស (មាត្រា៤ និងច្បាប់ទាំងមូល)** ៖ ក្នុងសេចក្តីព្រាងច្បាប់លើកទីបួនទាំងមូលនេះ មានការទទួលស្គាល់ថាសមាគមគឺមិនចាំបាច់តែនៅក្នុងស្រុកនោះទេ ជាលទ្ធផល នៅពេលដែលការយោងទៅក្នុងទិដ្ឋភាពនៃសង្គមស៊ីវិលក្នុងស្រុក ពាក្យ "ក្នុងស្រុក" បានលើកយកមកដាក់ពីក្រោមពាក្យថា "សមាគម" ៖ "*សមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល*" ។ ជាការឆ្លើយតប គឺមានការយោងទៅលើសេចក្តីព្រាងច្បាប់លើកទីបួនគឺ "*សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស*" ។ មិនតែប៉ុណ្ណោះក៏មានការទទួលស្គាល់ថា សមាគមអាចរួមមាន "នីតិបុគ្គល" និងមិនមែនត្រឹមតែ "រូបវន្តបុគ្គល" ដែលជាការបង្ហាញថារដ្ឋាភិបាលប្រហែលជាមានគំនិតគិតដល់អង្គការមានរចនាសម្ព័ន្ធត្រឹមត្រូវ និង/ឬ ចងសម្ព័ន្ធ។
- **និយមន័យនៃ "អង្គការសហគមន៍មូលដ្ឋាន" និង "សមាគម" (មាត្រា៥)** ៖ និយមន័យនៃពាក្យ "អង្គការសហគមន៍មូលដ្ឋាន" ត្រូវបានដាក់បន្ថែម ៖ "*ក្រុមប្រជាពលរដ្ឋដែលស្ម័គ្រចិត្តរួមគ្នាបង្កើត គ្រប់គ្រង និងធ្វើសកម្មភាពដោយខ្លួនឯង ដើម្បីបម្រើ និងការពារផលប្រយោជន៍ក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន*"។ ម.ស.ម.ក ស្វាគមន៍ចំពោះការទទួលស្គាល់ថា អង្គការសហគមន៍មូលដ្ឋាន ថាជាសង្គមស៊ីវិលមួយក្រុមទៀត ប៉ុន្តែនាពេលនេះមិនដឹងថាតើអ្វីជាភាពខុសគ្នាក្នុងការអនុវត្តន៍រវាងអង្គការសហគមន៍មូលដ្ឋាននិងសមាគមដែលមិនបានចុះបញ្ជី។ សមាគមដែលមិនបានចុះបញ្ជីប្រហែលជាមានបំណងរាប់បញ្ចូលនូវបណ្តាញក្រុមសង្គមស៊ីវិលដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ/ចងសម្ព័ន្ធ (សូមអានខាងលើ) ប៉ុន្តែគ្មានការបែកចែកបែបនេះជាចំហនោះទេ ។ ការព្រួយបារម្ភមួយស្តីពីការខុសប្លែក គឺសមាគមដែលមិនចុះបញ្ជី គឺពេលនេះត្រូវបានចែងថាអាច "*រៀបចំសកម្មភាពដើម្បីបម្រើប្រយោជន៍*

*សាធារណៈ"* មានលក្ខណៈស្រដៀងគ្នាច្រើនជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដូច្នេះជាលទ្ធផលអង្គការសហគមន៍មូលដ្ឋាន មិនអាចធ្វើបែបនោះបានទេ ដែលតាមពិតទៅពួកគេគួរតែអាចធ្វើបាន។ ជាងនេះទៅទៀត អង្គការសហគមន៍មូលដ្ឋានហាក់ដូចជាត្រូវបានកំណត់ដោយបទប្បញ្ញត្តិនេះដើម្បីអនុវត្តសកម្មភាពត្រឹមតែ *"ក្នុងមូលដ្ឋានរបស់ខ្លួន"* ។ ភាសានេះគួរតែមានការផ្លាស់ប្តូរដែលអានទៅជា *"ក្នុងមូលដ្ឋាន"* ដូច្នេះដើម្បីឲ្យអង្គការសហគមន៍មូលដ្ឋានមានសេរីភាពក្នុងការផ្លាស់ទី ឬ ធ្វើសកម្មភាពនៅកន្លែងណាក៏ដោយដែលពួកគេជ្រើសរើស ដោយយោងលើសិទ្ធិសេរីភាពនៃការផ្លាស់ទី និង ការជួបប្រជុំ។ ក្នុងករណីណាក៏ដោយ មាត្រា៥បានលើកលែងឲ្យអង្គការសហគមន៍មូលដ្ឋានមិនចាំបាច់ត្រូវចុះបញ្ជីក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដូចដែលបានពិភាក្សាខាងក្រោម ដូច្នេះ ពួកគេគួរតែមិនត្រូវបានកម្រិតដោយច្បាប់នេះទេ។ គួរតែមានការបញ្ជាក់បន្ថែមទៀត ក្នុងច្បាប់ស្តីពីនិយមន័យទាំងនេះ។

- **ការលុបចោលនូវបទប្បញ្ញត្តិចុះបញ្ជីជាដាច់ខាតតម្រូវដោយច្បាប់ ប៉ុន្តែមានតម្រូវការចុះបញ្ជីដើម្បីអាចទទួលបាន "សមត្ថភាពតាមផ្លូវច្បាប់" (មាត្រា៥) ៖** ទន្ទឹមនឹងពេលដែល ម.ស.ម.ក ស្វាគមន៍ចំពោះការលុបចោលបទប្បញ្ញត្តិចុះបញ្ជីជាដាច់ខាតតម្រូវដោយច្បាប់ ដោយយោងតាមការទទួលស្គាល់សិទ្ធិជាមូលដ្ឋាននៃសេរីភាពបញ្ចេញមតិ និងការជួបប្រជុំ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាចុះសច្ចាប័នក្នុងឆ្នាំ១៩៩២ និងបានបញ្ចូលទៅក្នុងច្បាប់ជាតិ ដូចដែលមានចែងក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ក៏ប៉ុន្តែនៅមានភាពមិនច្បាស់លាស់មួយចំនួន ចំពោះថាតើ "សមត្ថភាពតាមផ្លូវច្បាប់" មានន័យដូចម្តេច ហើយតើផលនៃសមត្ថភាពនេះអាចមានអ្វីខ្លះ។ សេចក្តីព្រួយបារម្ភបន្ថែមទៀត គឺភាពជំពាក់ជំពិនដែល អង្គការមិនមែនរដ្ឋាភិបាលមិនអាចចុះបញ្ជី និងធ្វើប្រតិបត្តិការក្នុងដែនកំណត់ដែលមានស្រាប់ក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្ននោះទេ។ ការបញ្ជាក់បន្ថែមទៀតលើបទប្បញ្ញត្តិនេះគឺត្រូវការជាចាំបាច់ គឺដើម្បីអាចចៀសវាងការយល់ច្រឡំចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងការរំលោភបំពានលើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដោយមិនចាំបាច់។
- **ការលើកលែងឲ្យអង្គការសហគមន៍មូលដ្ឋានពីការចុះបញ្ជីក្នុងច្បាប់នេះ (មាត្រា៥) ៖** ចាប់តាំងពីការផ្សព្វផ្សាយសេចក្តីព្រាងច្បាប់លើកទីមួយកាលពីមួយឆ្នាំមុន ម.ស.ម.ក មានការព្រួយបារម្ភអំពីការចុះបញ្ជីរបស់អង្គការសង្គមស៊ីវិលថ្នាក់មូលដ្ឋាន និងចលនាប្រជាពលរដ្ឋមិនផ្លូវការ។ ខណៈពេលដែលការលើកលែងបែបនេះ គឺហាក់ដូចជាការវិវឌ្ឍន៍មួយដ៏វិជ្ជមាន ប៉ុន្តែនៅតែអាចទុកចន្លោះឲ្យមានការបកស្រាយរបស់អាជ្ញាធរមូលដ្ឋាន ដោយសារតែក្នុងសេចក្តីព្រាងច្បាប់លើកទីបួនមានភាពមិនច្បាស់លាស់ថាអង្គការសហគមន៍មូលដ្ឋានពិតជាមានសមត្ថភាពតាមផ្លូវច្បាប់ ឬក៏អត់ (សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជីមិនមាន) ព្រោះថាក្នុងមាត្រា៥ អង្គការសហគមន៍មូលដ្ឋានទាំងនោះមិនតម្រូវឲ្យមានការចុះបញ្ជីនោះទេ។ មួយវិញទៀត ប្រយោគ *"លើកលែងតែមានការកំណត់តាមបទប្បញ្ញត្តិនៃច្បាប់ដោយឡែក"* គឺជាការព្រួយបារម្ភមួយដែរ ៖ មានឱកាសដែលរដ្ឋាភិបាលអាចអនុម័ត "ប្រកាស" ឬក៏ច្បាប់បន្ទាប់បន្សំថែមទៀត ឬសូម្បីតែច្បាប់មួយផ្សេង

ទៀត ដែលកំណត់ជាកាតព្វកិច្ចឲ្យ អង្គការសហគមន៍មូលដ្ឋាន ត្រូវចុះបញ្ជីបន្ថែមទៀត នៅពេលដែលមិនសូវមានចំណាប់អារម្មណ៍ពីអ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិមកលើប្រធានបទនេះ ហើយរដ្ឋសភាក៏មិនអាចមានឱកាសពិនិត្យមើលលើច្បាប់ដែលមានអំណាចផ្នែកនីតិប្រតិបត្តិបែបនេះដែរ។ ចំណុចទាំងនេះគួរតែត្រូវបានបញ្ជាក់បន្ថែមក្នុងសេចក្តីព្រាងលើកក្រោយ។

- **ការជូនដំណឹងរបស់ អង្គការសហគមន៍មូលដ្ឋាន ៖** ទោះបីជា ប្រសិនបើយើងមើលលើច្បាប់នេះ គឺជាការគួរឲ្យសាទរ ដែលតម្រូវឲ្យមានត្រឹមតែការជូនដំណឹង ជាជាងតម្រូវឲ្យមានការសុំអនុញ្ញាត/ការយល់ព្រម ប៉ុន្តែក្នុងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី (ច្បាប់ស្តីពីបាតុកម្ម) អាជ្ញាធរមូលដ្ឋានបានអនុវត្ត និងបកស្រាយច្បាប់នេះខុស ចំពោះតម្រូវការឲ្យមានការជូនដំណឹង និងទាមទារឲ្យមានការសុំការអនុញ្ញាតិ ការរារាំង ឬបង្អាក់កម្មវិធីវេទិកាសាធារណៈរបស់ ម.ស.ម.ក នៅព្រៃឡង់ កាលពីពេលថ្មីៗនេះ គឺជាឧទាហរណ៍ជាក់ស្តែងដែលនាំឲ្យមានការព្រួយបារម្ភ។ ទោះបីជានេះគឺជាចំណុចនៃការអនុវត្តន៍ច្បាប់ ជាជាងការរិះគន់មកលើសេចក្តីព្រាងច្បាប់ដោយផ្ទាល់ ប៉ុន្តែច្បាប់នេះក៏បង្កលក្ខណៈងាយស្រួលឲ្យការអនុវត្តន៍ខុសៗបែបនេះអាចកើតឡើងផងដែរ ជាលទ្ធផលគឺនៅពេលដែលក្រុមកសិករមួយក្រុមតូច ឬក៏ក្រុមផ្សេងទៀតនៅមូលដ្ឋានត្រូវបានគេប្រាប់ថា ពួកគាត់មិនអាចបង្កើតអង្គការសហគមន៍មូលដ្ឋានបាននោះទេ ពេលនោះពួកគាត់នឹងគ្មានចំណេះដឹងចាំបាច់ដើម្បីតវ៉ាជាមួយនឹងការសម្រេចបែបនោះទេ។ ភាសាដែលប្រើក្នុងបទប្បញ្ញត្តិនេះគួរតែបញ្ជាក់ឲ្យបានច្បាស់ ឬក៏លុបចោលតែម្តង ដើម្បីការពារនូវការប្រើប្រាស់ ឬបកស្រាយខុសបែបនេះ។ ការពិត គឺសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនតម្រូវឲ្យមានការជូនដំណឹង បានធ្វើឲ្យកើតមានសំណួរថាហេតុអ្វីបានជា អង្គការសហគមន៍មូលដ្ឋានត្រូវតែធ្វើបែបនេះ ប្រសិនបើអង្គការទាំងនេះពិតជាត្រូវលើកលែងចេញពីតម្រូវការចុះបញ្ជីរបស់ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នេះទៅហើយនោះ (សូមអានខាងលើ) ។ យ៉ាងហោចណាស់ ការជូនដំណឹងបែបនេះគួរតែជាជម្រើសសម្រាប់ អង្គការសហគមន៍មូលដ្ឋាន។

- **បង្កើនប្រសិទ្ធភាពក្នុងបទប្បញ្ញត្តិចុះបញ្ជីដ៏ធ្ងន់ធ្ងរសម្រាប់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (មាត្រា ៧-២៧ នៃសេចក្តីព្រាងច្បាប់លើកទីបី) ៖** បទប្បញ្ញត្តិដែលមិនចាំបាច់មួយចំនួននៅក្នុងសេចក្តីព្រាងច្បាប់លើកទីបី ត្រូវបានលុបចោល ក្នុងសេចក្តីព្រាងលើកនេះ ជាលទ្ធផលបទប្បញ្ញត្តិចុះបញ្ជីដ៏ធ្ងន់ធ្ងរកាលពីមុន នឹងអាចទៅជាងាយស្រួល ឬក៏អាចចរចាបាន។ មួយវិញទៀត បទប្បញ្ញត្តិចុះបញ្ជីសម្រាប់អង្គការក្នុងស្រុក (មាត្រា៧-១៨ នៃសេចក្តីព្រាងច្បាប់លើកទីបី) និងសមាគមក្នុងស្រុក (មាត្រា១៩-២៧ នៃសេចក្តីព្រាងច្បាប់លើកទីបី) នៅទីនេះត្រូវបានដាក់បញ្ចូលគ្នាដើម្បីចៀសវាងការជាន់គ្នា/ដដែលៗ ដែលជាវិសោធនកម្មដែលគួរឲ្យស្វាគមន៍ចំពោះភាពច្បាស់លាស់។ ក៏ប៉ុន្តែ បន្ទាប់ពីការនិយាយបែបនេះ អង្គការមិនមែនរដ្ឋាភិបាលទំហំតូចដែលមានធនធាន និងសមត្ថភាពបន្តិចបន្តួច គឺនៅតែមើលឃើញថាដំណើរការចុះបញ្ជីគឺមានភាពធ្ងន់ធ្ងរដែលមិនអាចអនុវត្តតាមបាន និងមានអំណះអំណាងថាគួរតែមានប្រព័ន្ធចុះបញ្ជីពីរផ្សេងគ្នា ដែលឆ្លុះបញ្ចាំងពីភាពខុសប្លែកគ្នារវាងអង្គការធំ អង្គការ/សមាគមក្នុងស្រុក និងតូច អង្គការ/សមាគមថ្នាក់ខេត្ត។ មិនតែប៉ុណ្ណោះ នៅមានភាពមិនច្បាស់លាស់ថា ហេតុអ្វីចាំបាច់ត្រូវមានប្រវត្តិរូបសង្ខេបរបស់សមាជិក

ស្ថាបនិក (មាត្រា៧) ។ តម្រូវការបែបនេះ បង្ហាញថាការចុះបញ្ជីនឹងអាចត្រូវបានបដិសេធដោយផ្អែកលើប្រវត្តិរូបរបស់បុគ្គលម្នាក់ និយាយម្យ៉ាងទៀត រដ្ឋាភិបាលអាចងាយស្រួលក្នុងការជ្រើសរើសមើលថាតើនរណាដែលអាចបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលនេះគឺរំលោភដល់សិទ្ធិសេរីភាពជាសាកលក្នុងការបង្កើតសមាគម។ តម្រូវការបែបនេះគួរតែលុបចោល។

- **ការលុបចោលឯកសារយោងទៅលើ "ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ" (មាត្រា៦ និងបន្ទាប់ទៀត) ៖** សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងអស់ បច្ចុប្បន្នគួរតែអាចចុះបញ្ជីដោយផ្ទាល់នៅក្រសួងមហាផ្ទៃ ជាជាងការផ្តល់ជម្រើសឲ្យមានការចុះបញ្ជីនៅកម្រិតថ្នាក់ក្រោមជាតិ (ដូចជាមាត្រា៧ ក្នុងសេចក្តីព្រាងច្បាប់លើកទីបី) ។ ការវិវឌ្ឍន៍បែបនេះ ជំរុញឲ្យមានភាពជាប់លាប់ ប៉ុន្តែអាចបង្អាក់សុវត្ថិភាព ប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្តទាំងអស់ត្រូវមកចុះបញ្ជីនៅរាជធានីភ្នំពេញ។ ក្រសួងមហាផ្ទៃប្រហែលជាគិតថាខ្លួនមានកម្លាំងពលកម្មច្រើន និងមិនបានគិតដល់បន្ទុកការងារផ្នែករដ្ឋបាលដែលពាក់ព័ន្ធ។ ជាងនេះទៅទៀត ការធ្វើដំណើរទៅភ្នំពេញដើម្បីចុះបញ្ជី អាចរារាំងអង្គការដាច់ស្រយាលមួយចំនួនពីការចុះបញ្ជី។ លទ្ធភាពអាចចុះបញ្ជីជាមួយស្ថាប័នថ្នាក់ក្រោមជាតិគួរតែត្រូវបង្កើតមានសាជាថ្មី។
- **ការកែប្រែតម្រូវការចំនួនអ្នកចាប់ផ្តើមបង្កើតដែលមិនសមរម្យ និងមិនស្របច្បាប់សម្រាប់សមាគម (មាត្រា៦) ៖** ម.ស.ម.ក ស្វាគមន៍ចំពោះការលុបចោលនូវតម្រូវការចំនួនអ្នកចាប់ផ្តើមបង្កើតដែលមិនសមរម្យ និងមិនស្របច្បាប់ ដែលតម្រូវឲ្យមានប្រជាពលរដ្ឋកម្ពុជាចំនួន ១១នាក់ ជាសមាជិកស្ថាបនិក ដើម្បីបង្កើតសមាគម (មាត្រា៨ នៃសេចក្តីព្រាងច្បាប់លើកទីបី) ដែលពីមុនបង្កើតនូវចន្លោះប្រហោង ឬ "ការចាប់ ២២នាក់" ដែលក្រុមបុគ្គលក្រោម ១១នាក់ មិនអាចចុះបញ្ជីជាសមាគមនៅក្នុងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនេះ ហើយដូចដែលមានចែងក្នុងមាត្រា៦ នៃសេចក្តីព្រាងច្បាប់លើកទីបី ប្រសិនបើគ្មានការចុះបញ្ជីនឹងគ្មានសមាគមនោះទេ។ ការរារាំងបែបនេះគឺរំលោភលើសិទ្ធិសេរីភាពជាសាកលបង្កើតសមាគម។ ដោយកាត់បន្ថយចំនួនសមាជិកស្ថាបនិកចាប់ផ្តើមបង្កើតទៅត្រឹមតែបីនាក់ យោងតាមបទដ្ឋានអន្តរជាតិ ចន្លោះប្រហោងនេះអាចត្រូវបានកាត់បន្ថយ (ដោយសារតែមនុស្សពីរនាក់មិនត្រូវបានចាត់ទុកថាជាក្រុមនោះទេ) ។ ប៉ុន្តែនៅមានចំណុចបន្ថែមទៀត ៖ បទប្បញ្ញត្តិនេះគួរតែបញ្ជាក់ឲ្យច្បាស់ពី "បុគ្គល" (ដែលផ្ទុយនឹង "ប្រជាពលរដ្ឋ" ឬ "សញ្ជាតិ") ដើម្បីមិនរំលោភដល់សិទ្ធិជនដែលមិនមែនជាប្រជាពលរដ្ឋ ឧទាហរណ៍ដូចជា ជនដែលត្រូវជម្លៀស និងគ្មានទីជម្រក ដូចជាខ្មែរក្រោម និងកម្មករចំណាកស្រុកជាដើម។ មាត្រា២២(១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលចែងថា *"មនុស្សគ្រប់រូប"* មានសិទ្ធិបង្កើតសមាគម។ បទប្បញ្ញត្តិនេះគឺប្រឆាំងនឹងសិទ្ធិជាសាកល និងគួរតែត្រូវបានផ្លាស់ប្តូរ។
- **ការលុបចោលនូវការកំណត់ថ្លៃអាករចុះបញ្ជី និងថ្លៃអាករចុះបញ្ជី (មាត្រា១៣ និង២២ ក្នុងសេចក្តីព្រាងច្បាប់លើកទីបី ជាបន្តបន្ទាប់) ៖** ម.ស.ម.ក ស្វាគមន៍ការលុបចេញទាំងការកំណត់ថ្លៃអាករចុះបញ្ជី និងថ្លៃអាករចុះបញ្ជី (ដែលមិនបានចែកឲ្យដាច់រវាងចំណុចទាំងពីរ) ដែលកាលពីមុនមានការព្រួយបារម្ភពាក់ព័ន្ធនឹងតម្លាភាព ភាពសមាមាត្រ មជ្ឈត្តការ និងភាពជាប់លាប់ ដោយមិនទាន់គិតដល់ពីការព្រួយបារម្ភថាថ្លៃអាករបែបនេះ នឹងត្រូវបានប្រើជាកត្តារើសអើងប្រឆាំង និងមិនរាប់បញ្ចូលរាល់

អង្គការដែលមិនសូវមានធនធាន។ ប៉ុន្តែ លទ្ធភាពដែលអាចទៅបានគឺថា ការលុបចោលនូវតម្រូវការដើម្បីបង់ថ្លៃអាករបែបនេះ អាចនឹងបង្កឲ្យមានអំពើពុករលួយ ដែលជាជំងឺកំពុងតែរីករាលដាលនៅកម្ពុជា។ ដូច្នេះ គួរតែមានការបញ្ជាក់ឲ្យច្បាស់ និងបើកចំហថានឹងមិនតម្រូវឲ្យមានថ្លៃអាករបែបនេះនោះទេ ហើយប្រហែលជាយោងទៅលើបទប្បញ្ញត្តិក្នុងច្បាប់ប្រឆាំងនឹងអំពើពុករលួយដើម្បីដាក់ទោសចំពោះសកម្មភាពបែបនេះ ដូច្នេះរាល់ "ថ្លៃរត់ការ" ដែលមិនផ្លូវការទាំងឡាយនឹងត្រូវបានចាត់ទុកថាផ្ទុយពីច្បាប់។

- **ការកាត់បន្ថយតម្រូវការសម្រាប់ការផ្លាស់ប្តូរផ្នែករដ្ឋបាល (មាត្រា១០ និង១៨)** ៖ ម.ស.ម.ក ស្វាគមន៍ចំពោះការពិតដែលថា បច្ចុប្បន្នមានតែតម្រូវការផ្នែករដ្ឋបាលសំខាន់ៗតែប៉ុណ្ណោះដែលតម្រូវឲ្យរាយការណ៍ទៅកាន់ក្រសួងមហាផ្ទៃ ឬក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានដូចជា ការកែប្រែលក្ខន្តិកៈរបស់ស្ថាប័ន (ក្នុងករណីនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកតែប៉ុណ្ណោះ) ឬក៏ផ្លាស់ប្តូរការិយាល័យ ឬប្រធាន/នាយកប្រតិបត្តិ។ មាត្រា៨៤ នៃសេចក្តីព្រាងច្បាប់លើកទីបី គឺមានភាពធ្ងន់ធ្ងរជាងនឹងចំណុចនេះ។
- **ការលុបចោលនូវតម្រូវការដែលឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលផ្តល់នូវច្បាប់ចម្លងនៃរបាយការណ៍ធនាគារ (មាត្រា១៥ ក្នុងសេចក្តីព្រាងច្បាប់លើកទីបី)** ៖ ពេលនេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានការលើកលែងមិនចាំបាច់ត្រូវផ្តល់នូវច្បាប់ចម្លងនៃរបាយការណ៍ធនាគារបន្ទាប់ពីមានការចុះបញ្ជី ដែលជាចំណុចគួរឲ្យស្វាគមន៍ ទោះបីជាមិនមានការច្បាស់លាស់ថាហេតុអ្វីបានជារដ្ឋាភិបាលមានការព្រួយបារម្ភខ្លាំងចំពោះការរៀបចំមូលនិធិ របស់អង្គការបរទេសដែលនៅតែតម្រូវឲ្យផ្តល់ព័ត៌មានប្រភេទនេះ (មាត្រា១២) ថ្វីបើឥឡូវនេះមានឱកាសអាចផ្តល់នូវ "ហេតុផលសមរម្យ" ប្រសិនបើពួកគេមិនអាចធ្វើបែបនេះបានក្នុងរយៈពេល ៣០ថ្ងៃ។
- **ការលុបចោលកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការផ្តល់វិក្កយបត្រចុះបញ្ជី (មាត្រា១៦ និង៣១ ក្នុងសេចក្តីព្រាងច្បាប់លើកទីបី)** ៖ បច្ចុប្បន្ន ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មិនជាប់កាតព្វកិច្ចចេញនូវវិក្កយបត្រចុះបញ្ជីឲ្យស្ថាប័ន ដែលអាចកាត់បន្ថយនូវការិយាល័យធិបតេយ្យ ប៉ុន្តែស្របពេលជាមួយគ្នាដែរបានលើកសំណួរទាក់ទងនឹងអំពើពុករលួយជាថ្មីម្តងទៀត វិក្កយបត្រផ្លូវការគឺជាវិធីដ៏ល្អមួយក្នុងការបង្ការការប៉ុនប៉ងប្រព្រឹត្តអំពើពុករលួយ។ ពិសេសជាងនេះទៅទៀត ម.ស.ម.ក មានការព្រួយបារម្ភថាការលុបចោលបែបនេះ អាចមានន័យថាអង្គការដែលត្រូវបានជូនដំណឹងថាបរាជ័យ ឬខកខានមិនបានចុះបញ្ជី ដែលការពិតគឺពួកគេបានដាក់ពាក្យសុំចុះបញ្ជីរួចទៅហើយ ដូច្នេះពួកគេនឹងអាចត្រូវបានប្រាប់ឲ្យចុះបញ្ជីសាជាថ្មី ដំណើរការនេះល្អបំផុតនឹងអាចត្រឹមតែពន្យារពេលពួកគេ តែធ្ងន់ធ្ងរបំផុតនោះគឺរារាំងពួកគេពីការទទួលបាន "*សមត្ថភាពស្របច្បាប់*"។
- **កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល ជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស (មាត្រា១៤)** ៖ ការអះអាងដោយបើកចំហលើការពិតដែលរដ្ឋាភិបាលប្រហែលជាសម្រេចមិនគាំទ្រគម្រោងជំនួយរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវបានដកចេញ (មាត្រា៣៣ ក្នុងសេចក្តីព្រាងច្បាប់លើកទីបី) ខណៈពេលដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស

ដែលមិនមានដៃគូជាមួយ ក្រសួង/ស្ថាប័នរដ្ឋាភិបាល ពេលនេះនឹងអាចបង្កើតជាអនុស្សរណៈដោយផ្ទាល់ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការបរទេស។ ការបង្កើតនូវជំហាននេះ ហាក់ដូចជាបង្កើតឡើងដើម្បីសម្រួលការងាររបស់អង្គការបរទេសនៅកម្ពុជា ក៏ប៉ុន្តែវិសោធនកម្មទាំងនេះបានកែលម្អច្រើន ៖ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសនៅតែត្រូវ "ពិភាក្សាឯកភាពជាមួយក្រសួង/ស្ថាប័នរបស់រាជរដ្ឋាភិបាលលើគម្រោងជំនួយនានា មុននឹងដាក់ពាក្យសុំចុះអនុស្សរណៈ..." ខណៈដែលមាត្រា១២ តម្រូវឲ្យពួកគាត់បញ្ជូន "លិខិតដែលចេញដោយក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីគាំទ្រគម្រោងជំនួយនេះ..."។ ការអនុញ្ញាតរបស់រដ្ឋាភិបាលនៅកម្រិតខ្ពស់បែបនោះអាចនឹងត្រូវបានគេប្រើយ៉ាងងាយស្រួលដើម្បីបង្អាក់ទឹកចិត្តរបស់អង្គការតស៊ូមតិបរទេស។ បន្ថែមពីលើនោះ ក៏រួមមានការដកចេញពីមាត្រា៣៣ ក្នុងសេចក្តីព្រាងច្បាប់លើកទីបី ដែលតម្រូវឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការបរទេសផ្តល់ជា "ការបញ្ជាក់ជាលាយលក្ខណ៍ពីមូលហេតុនៃការបដិសេធ [ការចុះអនុស្សរណៈ] ដែលស្របជាមួយនឹងដំណើរការដែលអាចអនុវត្តបានចំពោះអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក គឺគួរឲ្យសោកស្តាយណាស់។ តម្លាភាពគួរតែអនុវត្តឲ្យបានជាប់លាប់ក្នុងគ្រប់កម្រិតទាំងអស់នៃការធ្វើការសម្រេចចិត្ត (សូមអានផ្នែក ២(២) ខាងក្រោម) ។

- **ការលុបចោលបទប្បញ្ញត្តិស្តីពីបុគ្គលភាពគតិយុត្តរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស (មាត្រា៣៥) ៖** ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនបានបកស្រាយនូវតម្រូវការចំពោះអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលនឹងត្រូវបានទទួលស្គាល់ថាជានីតិបុគ្គលបរទេសទៀតនោះទេ នេះ ប្រហែលជាបទប្បញ្ញត្តិបែបនេះមិនមានឥទ្ធិពលចំពោះស្ថានភាពរបស់អង្គការបែបនោះ៖ ទោះបីជាកម្ពុជាទទួលស្គាល់ ឬ មិនទទួលស្គាល់ថាពួកគេជានីតិបុគ្គលក៏ដោយ ពួកគេនៅតែមានបំណងធ្វើសកម្មភាពនៅកម្ពុជា ហើយដូច្នេះកម្ពុជាគួរតែចាត់ទុកពួកគេថាជានីតិបុគ្គលមួយដែរ ទោះបីជាពួកគេជាអ្វីក៏ដោយ។ បទប្បញ្ញត្តិបែបនេះក៏ហាក់ដូចជាចំណុចបន្ថែមដែលមិនចាំបាច់ ដោយសារតែមាននិយមន័យរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេសក្នុងមាត្រា៤ រួចទៅហើយ។
- **ការលុបចោលនូវតម្រូវការដែលរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលបរទេសធ្វើ "កិច្ចសហការ" (មាត្រា៣៦ ក្នុងសេចក្តីព្រាងច្បាប់លើកទីបី) ៖** តម្រូវការមួយនេះគឺហាក់ដូចជាធ្ងន់ធ្ងរដោយមិនសមហេតុផលចំពោះអង្គការមិនមែនរដ្ឋាភិបាលបរទេស និងដកហូតយកនូវសិទ្ធិសេរីភាពបញ្ចេញមតិ និងការបង្កើតសមាគមរបស់ពួកគេ។ ម.ស.ម.ក ស្វាគមន៍ចំពោះវិសោធនកម្មមួយនេះ ទោះបីជាចំណុចទាំងនេះគួរតែស្របជាមួយនឹងមាត្រា១២ និង១៤ (សូមអានខាងលើ) និងការរើសអើងទាំងអស់ប្រឆាំងនឹងអង្គការមិនមែនរដ្ឋាភិបាលបរទេស (សូមអានផ្នែក ២(១) ខាងក្រោម) ។
- **ការបញ្ជាក់ពីការផុតកំណត់នៃអនុស្សរណៈរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស (មាត្រា១៧) ៖** ការបញ្ជាក់ដ៏ច្បាស់លាស់ត្រូវបានបន្ថែមលើបទប្បញ្ញត្តិទាំងនេះ ដែលជាអ្វីគួរឲ្យស្វាគមន៍៖ អនុស្សរណៈពេលនេះត្រូវបានចែងថា "សុពលភាពរបស់អនុស្សរណៈនឹងត្រូវបញ្ចប់ជាស្វយប្រវត្តិក្រោយថ្ងៃផុតកំណត់" ដែលនេះគឺសមរម្យហើយ ហើយដែលសំណាញ់សុវត្ថិភាពរយៈពេលពីរខែសម្រាប់អង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលហួសកំណត់រយៈពេលបន្តសុពលភាពចំនួន ៩០ថ្ងៃ (មុនពេលផុតកំណត់) ត្រូវបានដកចេញ ប្រហែលដោយសារតែគ្មានហេតុផលអ្វីដែលធ្វើឲ្យអង្គការ

មិនមានសមត្ថភាពក្នុងការធ្វើបានទាន់ពេលនោះ។ ក៏ប៉ុន្តែ តម្រូវការឲ្យ "*ដាក់សំណើសុំពន្យារសុពលភាពរបស់អនុស្សរណៈ*" គឺពិតជាធ្ងន់ធ្ងរដោយមិនសមហេតុផល។ អង្គការមិនមែនរដ្ឋាភិបាលបរទេសគួរត្រឹមតែជូនដំណឹងដល់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការពន្យារសុពលភាព ជាជាងសុំការអនុញ្ញាត។ ជាងនេះទៅទៀត រយៈពេលដែលអង្គការមិនមែនរដ្ឋាភិបាលបរទេសអាចចុះបញ្ជីត្រូវបានកម្រិតត្រឹម បីឆ្នាំ រយៈពេលប្រាំឆ្នាំគួរតែសមរម្យជាង។

- **លទ្ធភាពថ្មីរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការបញ្ចប់សុពលភាពអនុស្សរណៈ ដោយផ្អែកលើមូលដ្ឋានផ្សេងៗ (មាត្រា១៧)** ៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានលទ្ធភាពបញ្ចប់សុពលភាពអនុស្សរណៈរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ដោយផ្អែកលើមូលដ្ឋាននៃការរៀបចំសកម្មភាពដែល "ប៉ះពាល់ដល់សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់របស់សង្គមជាតិកម្ពុជា" មូលដ្ឋានដែលបានទៅហួសពីការហាមឃាត់បុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលបរទេសចូលរួមក្នុងសកម្មភាពប្រហាក់ប្រហែលគ្នានេះ ដូចមានចែងក្នុងអនុស្សរណៈបទដ្ឋានបច្ចុប្បន្នរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ បន្ថែមពីលើនោះ មិនមានការបញ្ជាក់ពីលទ្ធភាពនៃការលុបចេញពីបញ្ជីរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ក្នុងអនុស្សរណៈបច្ចុប្បន្ននោះទេ។ ខណៈពេលដែលបទប្បញ្ញត្តិនេះមិនសូវជាខុសគ្នាប៉ុន្មានក្នុងអ្វីដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ មាត្រា៥២ ដែលសំដៅលើ "*សន្តិសុខជាតិ...ទំនៀមទម្លាប់ដ៏ល្អរបស់ប្រទេស...ច្បាប់...សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម...[និង] ការខិតខំប្រឹងប្រែងដែលអភិវឌ្ឍសុខមាលភាព និងបទដ្ឋានរស់នៅរបស់ប្រជាពលរដ្ឋ*" ដែលអាចត្រូវបានគេប្រើខុស បំពាន និងការបកប្រែដ៏ទូលំទូលាយ ដែលបទប្បញ្ញត្តិនេះបានបង្កើតឲ្យមាន ហើយដូច្នេះអាចបង្កឲ្យមានការព្រួយបារម្ភជាខ្លាំងចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។ ចំណុចនេះអាចផ្តល់នូវភាព"ស្របច្បាប់" ចំពោះបទពិសោធន៍នៃការបណ្តេញចេញអង្គការបរទេសតស៊ូមតិ និងសិទ្ធិមនុស្សកាលពីមុន និងបច្ចុប្បន្ន (ដូចជា ក្លូបិល វីតណេស) ។ ចុងក្រោយ ពាក្យសម្តីដែលប្រើគួរតែត្រូវបានធ្វើវិសោធនកម្ម ដើម្បីឲ្យអនុលោមតាមរដ្ឋធម្មនុញ្ញ ប៉ុន្តែគួរតែអនុម័តនូវការសាកល្បងទាំងបី ក្នុងមាត្រា ២២(២) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានដូចជាការរិតត្បិតលើសេរីភាពការបង្កើតសមាគមគួរតែត្រូវ (១) "*ចែងដោយច្បាប់*"(២) "*មានភាពចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ*" និង (៣) "*ដើម្បីជាប្រយោជន៍ដល់សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សង្គម ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ*" ។ បញ្ហាមួយទៀតដែលគួរឲ្យព្រួយបារម្ភគឺថាតើនរណាជាអ្នកសម្រេចលើសកម្មភាពអ្វីខ្លះដែលបំពាន លក្ខខណ្ឌ (ដ៏ទូលំទូលាយ) នេះ ដូចចែងក្នុងមាត្រា១៧។

- **ការធ្វើឲ្យវិសាលភាពតូចចង្អៀតនៃសកម្មភាពដែលការចុះបញ្ជី ឬការចុះអនុស្សរណៈអាចឲ្យសមាគម ឬក៏អង្គការមិនមែនរដ្ឋាភិបាលអាចធ្វើសកម្មភាពទៅបាន (មាត្រា២២ និង២៣)៖** "សិទ្ធិទទួលបានពីការចុះបញ្ជី"ជាច្រើន (ឧ. សកម្មភាពដែលត្រូវបានអនុញ្ញាត) ដែលបានចែងក្នុងមាត្រា ៤០ នៃសេចក្តីព្រាងច្បាប់លើកទីបី ("សិទ្ធិជានីតិបុគ្គលនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល") ដូចជាលទ្ធភាពក្នុងការទទួលបានវិភាគទានហិរញ្ញវត្ថុ បើកគណនីធនាគារ ជួលអចលនទ្រព្យ ។ល។ បើអានជាដំបូងហាក់ដូចជាត្រូវបានគេលុបចោលហើយ ដោយនៅសល់តែអំណាចនៅក្នុងការចុះកិច្ចសន្យា(មាត្រា២២) *"ការជ្រើសរើសបុគ្គលិក ឬកម្មករខ្មែរដើម្បីបម្រើការងារ"* (មាត្រា២៣) ដែលត្រូវបានហាមឃាតនៅពេលនេះនៅក្នុងករណីមិនបានចុះបញ្ជី បើនិយាយម្យ៉ាងទៀត អង្គការមួយត្រូវតែចុះបញ្ជីដើម្បីអាចមានសិទ្ធិចុះកិច្ចសន្យា ឬជ្រើសរើសបុគ្គលិកក្នុងនាមរបស់ខ្លួន។ ការផាត់ចេញទាំងនេះ ហាក់ដូចជាដោយបំពាន៖ ការណ៍នេះគឺមិនមានភាពច្បាស់លាស់ឡើយ ឧទាហរណ៍កិច្ចសន្យាប្រភេទណាពិតប្រាកដ ដែលរដ្ឋាភិបាលចង់សំដៅក្នុងមាត្រា២២។ ទោះបីប្រហែលជាមិនមានហេតុផលសមស្របក្នុងការហាមឃាត់ ក៏ប៉ុន្តែដោយសារតែបុគ្គលម្នាក់ៗមានសិទ្ធិក្នុងការចុះកិច្ចសន្យាក្នុងនាមផ្ទាល់ខ្លួនដោយទទួលខុសត្រូវលើហានិភ័យ និងត្រូវមានទំនួលខុសត្រូវ បទប្បញ្ញត្តិហាមឃាត់ទាំងនេះត្រូវតែលុបចេញពីសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនាពេលខាងមុខ ដោយហេតុថាអង្គការណាក៏ដោយគួរតែមានសេរីភាពក្នុងការចុះកិច្ចសន្យា និងជ្រើសរើសបុគ្គលិក/កម្មករ ដូចគ្នានឹងអ្វីដែលវិស័យពាណិជ្ជកម្ម និងបុគ្គលធ្វើដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការជ្រើសរើសបុគ្គលិក និងកម្មករ ត្រូវតែស្របទៅនឹងគម្រោងជំនួយរបស់អង្គការ (មាត្រា៤១ នៃសេចក្តីព្រាងលើកទីបី) គឺត្រូវបានបោះបង់ចោលហើយ ដែលការណ៍នេះគួរតែទទួលបាននូវការស្វាគមន៍ ដោយសារថាប្រការនេះអនុញ្ញាតឲ្យអង្គការនានាអាចបង្កើនការបត់បែនបានងាយស្រួល។
- **ការលុបចោលបទប្បញ្ញត្តិដែលទាក់ទងនឹងការបើកទីស្នាក់ការសាខា(មាត្រា៤៣ នៃសេចក្តីព្រាងលើកទីបី)៖** បទប្បញ្ញត្តិដែលអនុញ្ញាតិឲ្យអង្គការនានាអាចបើកទីស្នាក់ការសាខាគឺត្រូវបានគេលុបចោល។ ទោះបីជាមិនមានអ្វីដែលនិយាយពីបញ្ហានេះនៅក្នុងសេចក្តីព្រាងលើកទីបួន ដើម្បីស្នើឲ្យមានការ ពិនិត្យលើការលុបចោលនេះក៏ដោយ ក៏ប៉ុន្តែការលុបចោលបទប្បញ្ញត្តិជាលាយល័ក្ខអក្សរដែលអនុញ្ញាតឲ្យបើកស្នាក់ការសាខា គឺធ្វើឲ្យមានក្តីបារម្ភថាអង្គការនានានឹងមិនអាចបើកទីស្នាក់ការសាខារបស់ខ្លួនបាន ដែលប្រការនេះរំលោភលើសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ពួកគេក្នុងការបង្កើតសមាគម។ ដូច្នេះហើយបទប្បញ្ញត្តិត្រូវតែចែងឡើងវិញ។
- **ការលុបចោលការបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក្រសួងសេដ្ឋកិច្ច) និងអាជ្ញាធរសវនកម្មជាតិ (មាត្រា៤៨សេចក្តីព្រាងលើកទី៣)៖** មិនមានបទប្បញ្ញត្តិដែលផ្តល់ឲ្យក្រសួងសេដ្ឋកិច្ច និង/ឬ អាជ្ញាធរសវនកម្មជាតិ នូវសិទ្ធិក្នុងការត្រួតពិនិត្យរបាយការណ៍ស្ថានភាព និងទ្រព្យហិរញ្ញវត្ថុរបស់អង្គការ ទោះជាយ៉ាងណាក៏ដោយការលុបចោលបទប្បញ្ញតិក៏បណ្តាលឲ្យមានការលុបចោលនូវការតម្រូវថាស្ថាប័នទាំងពីរផ្តល់ការជូនដំណឹងរយៈពេលពីរសប្តាហ៍មុនដល់អង្គការដែលពាក់ព័ន្ធ។

រដ្ឋាភិបាលត្រូវផ្តល់ការបញ្ជាក់ថាតើខ្លួននៅតែមានបំណងរក្សាសមត្ថកិច្ចរបស់ស្ថាប័នទាំងពីរនេះឬយ៉ាងណា ប្រសិនបើដូច្នេះ បទប្បញ្ញត្តិនៃការជូនដំណឹងត្រូវតែរក្សាទុកនៅដដែល និងពង្រីកវិសាលភាព។

- **វិសោធនកម្មនៃ"ការជូនដំណឹង" ទៅជា "ការស្នើសុំ" ក្នុងករណីដែល អង្គការបរទេស និងសមាគមនានាចង់បញ្ចប់អនុស្សារណៈរបស់ពួកគេ (មាត្រា២៧)៖** ការធ្វើវិសោធនកម្មនេះគឺបន្ថែមបន្ទុកថែមទៀតទៅលើនីតិវិធី៖ អង្គការបរទេសនានាត្រូវតែមានសេរីភាពក្នុងការបញ្ចប់អនុស្សារណៈរបស់ខ្លួន – តាមរយៈការជូនដំណឹងជាមុន– តាមរបៀបដែលបានចែងក្នុងសេចក្តីព្រាងលើកទីបី។
- **ការលុបចោលបទប្បញ្ញត្តិនានាទាក់ទងនឹងការអនុវត្តន៍សេចក្តីសម្រេចរបស់តុលាការ(មាត្រា២៦ និង ២៧)៖** បទប្បញ្ញត្តិនានាដែលរៀបរាប់ពីនីតិវិធីអនុវត្ត ដោយ*"គ្រប់ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់"* នៃសេចក្តីសម្រេចរបស់តុលាការ ដើម្បីផ្អាក រំលាយ ឬបញ្ចប់សកម្មភាពអង្គការត្រូវបានលុបចោល។ មិនមានភាពច្បាស់លាស់ថាហេតុអ្វីបានជាបទប្បញ្ញត្តិទាំងនេះត្រូវបានលុបចោលនោះទេ – នេះប្រហែលជាមានការសន្មតថារាល់សេចក្តីសម្រេចរបស់តុលាការ ត្រូវតែអនុវត្តដោយគ្រប់ភាគីពាក់ព័ន្ធ។
- **ការបញ្ចូលដោយ ការយោងទៅលើ*"ការរំលាយតាមសេចក្តីសម្រេចរបស់តុលាការ"* (មាត្រា២៨)៖** បទប្បញ្ញត្តិនេះគឺមិនស្របនឹងបទប្បញ្ញត្តិដទៃទៀតនៅក្នុងសេចក្តីព្រាង ដែលរៀបនឹងអនុម័តជាច្បាប់ជាធរមាននេះ ដោយចែងអំពី *"ការរំលាយ"* អង្គការដោយ "*តុលាការ*"។ មាត្រា២៦ និងផ្នែកទីមួយនៃមាត្រា២៨ ចែងអំពីការរំលាយដោយស្ម័គ្រចិត្ត ទោះបីជាមានការចែងយ៉ាងច្បាស់នៅក្នុងមាត្រា២៦ ថាសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការរំលាយបែបនេះ គឺត្រូវតែផ្ញើទៅក្រសួងមហាផ្ទៃ។ ទោះបីជា ម.ស.ម.ក ស្វាគមន៍ចំពោះការលើកឡើងថា ប្រព័ន្ធយុត្តាធិការត្រូវតែជាអ្នកដាក់ទណ្ឌកម្មជាជាងអង្គនីតិប្រតិបត្តិ (ប៉ុន្តែដោយសារតែតុលាការខ្វះឯករាជ្យភាព នោះស្ថាប័នឯករាជ្យមួយដែលមានលក្ខណៈដូចតុលាការគួរតែត្រូវបានបង្កើតឡើង) ស្ថានភាពបែបនេះមិនអាចយកទៅអនុវត្តបានក្នុងបរិបទនៃការរំលាយដោយស្ម័គ្រចិត្តបានឡើយ ហើយការណ៍នេះនឹងបង្កឲ្យមានលទ្ធភាពគួរឲ្យខ្លាច – ផ្ទុយមកវិញត្រូវបានគេដាត់ចេញពីសេចក្តីព្រាងលើកទី៤ – ថាអង្គការនិងសមាគមអាចត្រូវបានរំលាយទាំងស្រុង (ជាជាងត្រូវបានគេលុបចេញពីបញ្ជី) សូម្បីក្នុងករណីថាតុលាការគឺជាអ្នកអាចសម្រេចសេចក្តីលើបញ្ហានេះ។ ប្រសិនបើលទ្ធភាពបែបនេះត្រូវបានគេគ្រោងចង់បាននោះ –ជាជាងការដោយបាំងមុខដើម្បីរំលាយដោយឈរលើមូលដ្ឋាននៃសកម្មភាពឧក្រិដ្ឋ – បទប្បញ្ញត្តិនេះហាក់ដូចជាអនុញ្ញាតឲ្យមានវិធីសាស្រ្តបន្ថែម និងដាច់ដោយឡែកផ្សេងទៀត ក្នុងការប្រកាសថាសកម្មភាពរបស់អង្គការមួយចំនួនគឺខុសច្បាប់ ហើយក៏យោងទៅមាត្រា៣០ និង៣១។ លើសពីនេះទៀត លក្ខខណ្ឌក្នុងការរំលាយ គឺមិនត្រូវបានចែងឲ្យបានច្បាស់លាស់ក្នុងមាត្រាណាមួយឡើយ – នេះគឺជាការបំភ្លេចចោលដ៏គួរឲ្យបារម្ភបំផុត។ លទ្ធផលអាចថា សមាគមមួយ ឬក៏អង្គការមួយ អាចនឹងត្រូវបានគេរំលាយទាំងស្រុង (ដោយគ្មានការពន្យល់ និងគ្មាននីតិវិធីតវ៉ា) – ការរំលាយនេះគួរតែជាតុលាការ ហើយមិនមែនជាអង្គនីតិប្រតិបត្តិនោះទេ ដែលបញ្ហាបែបនេះ (ជាការវិវត្តន៍មួយប៉ុន្តែគ្រាន់តែជាចំណុចតូចមួយប៉ុណ្ណោះ ដោយសារតែមិនមានលក្ខខណ្ឌជាក់លាក់

ឡើយថាតើតុលាការត្រូវឈរលើមូលដ្ឋានអ្វីដើម្បីធ្វើសេចក្តីសម្រេច)។ គេត្រូវតែធ្វើការកែប្រែមាត្រា ២៨ ដើម្បីធានាភាពច្បាស់លាស់ និងភាពស្របគ្នា និងដើម្បីការពារប្រឆាំងនឹងសេចក្តីព្រួយបារម្ភដែលនឹងកើតមានឡើង។

- **ការកែប្រែបទប្បញ្ញត្តិព្រហ្មទណ្ឌ និងនីតិវិធី (មាត្រា៣០ និង៣១)៖** បទប្បញ្ញត្តិព្រហ្មទណ្ឌ និងនីតិវិធីត្រូវបានកែប្រែ ដែលរាប់ទាំងឈ្មោះរបស់ជំពូកនេះផងដែរ ដែលបានដាក់ថា *"វិធានការរដ្ឋបាល"* ដែលជាក្តីបារម្ភ គន្លឹះមួយក្នុងចំណោមក្តីបារម្ភទាំងឡាយរបស់ម.ស.ម.ក ពោលគឺថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលអាចផ្តល់សិទ្ធិឲ្យក្រសួងនានា (ឧ. អង្គនីតិប្រតិបត្តិ) ដើម្បីសម្រេចចិត្តដ៏មានសារៈសំខាន់ក្នុងការលុបអង្គការ ឬសមាគមមួយចេញពីបញ្ជី ក៏ដូចជាចេញវិធានការណ៍រដ្ឋបាល ជាជាងទទួលបានសេចក្តីសម្រេចពីតុលាការ ឬ យ៉ាងហោចណាស់ទៅស្ថាប័នឯករាជ្យមួយដែលមានលក្ខណៈដូចតុលាការ។ បន្ថែមលើសពីនេះទៀត ទាក់ទងនឹងអង្គការក្នុងស្រុក វិធានការអន្តរការដែលចែងពីការផ្អាកសកម្មភាពអង្គការពី មួយខែទៅបីខែ ត្រូវបានគេលុបចោលហើយ ដើម្បីជាប្រយោជន៍ដល់រយៈពេលព្រមានបន្ថែមបីខែ ដែលត្រូវស្របជាមួយនឹងការតម្រូវនានាមុនពេលដែលការលុបឈ្មោះចេញពីបញ្ជីទាំងស្រុងចូលជាធរមាន នេះជាទណ្ឌកម្មថ្មីដែលចែងក្នុងសេចក្តីព្រាងច្បាប់លើកទី៤។ យើងសូមស្វាគមន៍ចំពោះការរំសូបន្ធូរបន្ថយពីនីតិវិធីនៃការព្រមាន។ ការដាក់ជំនួសដោយលុបចេញពីបញ្ជី ចំពោះទណ្ឌកម្មពីមុនដែលផ្អាកសកម្មភាពរយៈពេលពីមួយខែទៅបីខែអាចជាការបំពាន ប៉ុន្តែដំណាក់កាលនៃការព្រមានមានគ្រប់គ្រាន់ ហើយការណ៍នេះមិនមែនគ្មានហេតុផលសមស្រប ឬ ក៏មិនសមមូលដើម្បីស្នើថាសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនឹងត្រូវបានដាក់ទោសពីបទមិនគោរពតាមច្បាប់ (ទោះបីជាគ្មានមូលហេតុនៃការផ្អាកសកម្មភាពមិនអាចត្រូវបានរក្សាទុកជាទណ្ឌកម្មដែលមានលក្ខណៈធូរស្រាលជាង)។ ក៏ប៉ុន្តែនិតិវិធីតវ៉ាគួរតែត្រូវបញ្ចូលដើម្បីធានាថាអង្គការនានាអាចបន្តសកម្មភាពរបស់ខ្លួនបាន។ ទោះបីជាមានក្តីព្រួយបារម្ភគួរជាទីកត់សម្គាល់ទាំងនេះក៏ដោយ ម.ស.ម.ក ស្វាគមន៍ចំពោះកម្រិតនៃភាពច្បាស់លាស់ដែលបានដាក់បញ្ចូលនៅក្នុងបទប្បញ្ញត្តិនេះនៅពេលនេះ។
- **ការលុបចោលដែលអាចឲ្យមាន *"ការរំលោភលក្ខន្តិកៈ ឬអនុស្សារណៈ"* (មាត្រា៥៤ នៃសេចក្តីព្រាងលើកទី៣)៖** ម.ស.ម.ក ស្វាគមន៍ចំពោះការដកចេញនូវទណ្ឌកម្មនេះ ព្រោះថានេះគឺមានលក្ខណៈស្រពិចស្រពិលពេក ហើយអាចបើកឱកាសឲ្យមានការអនុវត្តន៍ច្បាប់ខុស និងបំពាន ជាពិសេសដោយយោងទៅលើការដាក់ទណ្ឌកម្មមិនមានភាពមិនច្បាស់លាស់ *"ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន"*។
- **ការកែប្រែបទប្បញ្ញត្តិអន្តរកាល (មាត្រា៣២)** ៖ ម.ស.ម.ក ស្វាគមន៍ចំពោះការផ្លាស់ប្តូរនៃបទប្បញ្ញត្តិអន្តរកាល៖ មិនមែនគ្រាន់តែជា *"ការជូនដំណឹងជាលាយលក្ខណ៍អក្សរ"* ដែលជាការតម្រូវចម្បងសម្រាប់ប្រតិបត្តិការដែលត្រូវបានបន្តនោះទេ ជាងនោះទៅទៀតគឺ *"ការរៀបចំសំណុំឯកសារសម្រាប់ការចុះបញ្ជីឡើងវិញ"* ដូចដែលបានចែងក្នុងសេចក្តីព្រាងលើកទីបី ប៉ុន្តែការតម្រូវឲ្យផ្តល់នូវព័ត៌មានលម្អិតសំខាន់ៗរបស់អង្គការ គឺមិនសមហេតុផលឡើយ ដោយសារតែចំនួននៃ អង្គការ "ខ្មោច" ដែលបានឈប់ដំណើរការក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩៣មក ប៉ុន្តែបន្តមានឈ្មោះ ជាការពិតដែល

វាក្យសព្ទត្រូវបានកែប្រែដោយឆ្លុះបញ្ចាំងពីបញ្ហានេះ នៅក្នុងចុងបញ្ចប់នៃមាត្រា៣២ *"ក្រសួងមហាផ្ទៃចាត់ទុកថា សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះបានបោះបង់សកម្មភាពរបស់ខ្លួនហើយ"។* ទោះជាយ៉ាងណាក៏ដោយ ក្រសួងមហាផ្ទៃត្រូវជូនដំណឹងដល់អង្គការពាក់ព័ន្ធទាំងនោះមុនពេលលុបឈ្មោះរបស់ពួកគេចេញពីបញ្ជី ដោយហេតុថាមានអង្គការជាច្រើន ជាពិសេសសមាគមនៅតំបន់ដាច់ស្រយាល ប្រហែលជាមិនអាចបានដឹងអំពីលក្ខខណ្ឌតម្រូវឲ្យតម្កល់សំណុំលិខិតនៅក្រសួងមហាផ្ទៃនោះទេ។

## ២. ភាពព្រួយបារម្ភចម្បងចំនួនបីរបស់ម.ស.ម.ក

I. **អង្គការ និងសមាគមបរទេស៖** ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមិនអាចត ធ្វើឲ្យរឹតតែធ្ងន់ធ្ងរចំពោះសមាគម និងអង្គការបរទេសឡើយ៖ (ក) មាត្រា១៣មិនបានចែងអំពីហេតុផលក្នុងការបដិសេធពាក្យសុំអនុស្សរណៈឡើយ ដោយក្រសួងការបរទេស គ្មានកាតព្វកិច្ចផ្តល់សេចក្តីពន្យល់បកស្រាយអំពីសេចក្តីសម្រេចបែបនេះទេ ថ្វីបើជាការពិតដែលបទប្បញ្ញត្តិបែបនេះត្រូវបានបញ្ចូលក្នុងមាត្រា៣៣ នៃសេចក្តីព្រាងលើកទីបី ហើយក្រោយមកត្រូវបានគេលុបចេញ ឬ អង្គការក៏នឹងមិនអាចមានលទ្ធភាពក្នុងការប្តឹងតវ៉ានឹងសេចក្តីសម្រេចនេះឡើយ។ (ខ) មានកម្រិតមិនសមហេតុផលមួយនៃការយល់ព្រមរបស់រដ្ឋាភិបាលដែលត្រូវបានបញ្ញត្តិជាមួយនឹងការយោងទៅមាត្រា១២ និង១៤ ហើយយោងទៅតាមមាត្រា១២ និង១៥ អង្គការបរទេសគឺគ្រាន់តែមានសិទ្ធិក្នុងការអនុវត្តន៍ *"គម្រោងជំនួយ"* ដែលអាចត្រូវបានប្រើប្រាស់ដើម្បីបដិសេធ ឬក៏លុបអង្គការអន្តរជាតិចេញពីបញ្ជី ចំពោះទង្វើដែលត្រូវបានគេសន្មតថាបានរំលោភគោលបំណងនេះ ប្រសិនបើអង្គការទាំងនោះចូលរួមក្នុងកម្មវិធីតស៊ូមតិ ឬ កសាងសមត្ថភាព។ (គ) អង្គការបរទេសនានាត្រូវផ្តល់នូវលិខិតប្រកាសគណនីធនាគារ តាមមាត្រា១២ ដែលបទប្បញ្ញត្តិនេះមិនគ្របដណ្តប់អង្គការក្នុងស្រុកឡើយ។ (ឃ) បទប្បញ្ញត្តិនៃមាត្រា១៥ បានចែងអំពីប្រាក់ចំណាយបុព្វហេតុរដ្ឋបាល – រួមមានប្រាក់បៀវត្សរបស់បុគ្គលិកទាំងអស់[1] – មិនឲ្យលើសពី២៥ភាគរយនៃថវិកាសរុបរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស បុរេនិច្ឆ័យដោយលំអៀង លើអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើវិស័យតស៊ូមតិនិងកសាងសមត្ថភាព ហើយផ្តល់ការយកចិត្តទុកដាក់តាមការចូលចិត្តចំពោះអ្នកផ្តល់សេវាកម្ម។ (ង) អង្គការបរទេសមានកាតព្វកិច្ចត្រូវទទួលយល់ព្រមយ៉ាងហោចណាស់រៀងរាល់បីឆ្នាំដើម្បីបន្តប្រតិបត្តិការ ជាជាងគ្រាន់តែជូនដំណឹងជាមុន និង(ច) មាត្រា១៧ អាចបណ្តាលឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវបានគេលុបចេញពីបញ្ជីដោយឈរលើមូលដ្ឋានស្រពិចស្រពិលផ្សេងៗ ដែលអាចបើកឲ្យបានការរីករាលដាលការបកស្រាយនិងបោកបញ្ឆោត ជាថ្មីម្តងទៀតដោយគ្មានហេតុផល ឬ ក៏នីតិវិធីតវ៉ាច្បាស់លាស់ ដូច្នេះគេត្រូវតែធ្វើការកែប្រែបញ្ហានេះដោយស្របទៅតាមការពិនិត្យតាមបីដំណាក់កាលដែលចែងក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និង សិទ្ធិនយោបាយ។ វិសមភាពនៅក្នុងការអនុវត្តន៍បែបនេះ គឺជាការចង្អុលបង្ហាញអំពីការរើសអើងយ៉ាងធំធេងចំពោះសមាគម និងអង្គការបរទេស ហើយគេត្រូវតែប្រឆាំងនឹងវិសមភាពនេះ។

II. **ការចុះបញ្ជី៖** មាត្រា៨ និង១៣ ខកខានមិនបានចែងឲ្យបានច្បាស់លាស់អំពីការបដិសេធមិនឲ្យចុះបញ្ជី ឧ. ដោយគ្រាន់តែឈរលើមូលដ្ឋាននៃសំណុំលិខិត ដែលបានដាក់ជូនដើម្បីគាំទ្រការស្នើសុំចុះបញ្ជី ឬយ៉ាងណា។ ការពិនិត្យ *"នីត្យានុកូលភាព"* ដែលចែងក្នុងមាត្រា៨ មិនត្រូវ

[1] អនុស្សរណៈរបស់ក្រសួងការបរទេសបច្ចុប្បន្នរួមបញ្ចូលតែ បៀវត្សរបស់ថ្នាក់គ្រប់គ្រង និងបៀវត្សសម្រាប់ផ្នែករដ្ឋបាលប៉ុណ្ណោះទៅ ក្នុង "ប្រាក់ចំណាយបុព្វហេតុរដ្ឋបាល"។

បានគេផ្តល់អត្ថន័យទេ ដូច្នេះនេះគឺជាការបើកឲ្យមានការបញ្ជោត តើពាក្យថា "*នីត្យានុកូលភាពនៃលក្ខន្តិកៈ*" មានន័យយ៉ាងដូចម្តេច? នេះអាចជាការយោងទៅលើច្បាប់មួយចំនួននៅកម្ពុជា ដែលលក្ខន្តិកៈរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមិនបានអនុលោមទៅតាម ឬយោងទៅលើហេតុផល "នីត្យានុកូល" ផ្សេងទៀត។ ដូច្នេះការស្នើសុំចុះបញ្ជីគឺការបើកឲ្យមានលទ្ធភាព ដែលនឹងអាចត្រូវបានបដិសេធ ដោយឈរលើមូលដ្ឋានមិនច្បាស់មួយចំនួន ដែលមិនចាំបាច់ន អនុលោមទៅតាមស្តង់ដារអន្តរជាតិក្នុងការរិតត្បិតសេរីភាពសមាគម ជាពិសេសដូចជា ក្រសួងពាក់ព័ន្ធមិនមានកាតព្វកិច្ចក្នុងការផ្តល់សេចក្តីពន្យល់ជាលាយលក្ខណ៍អក្សរ ចំពោះការសម្រេចបដិសេធរបស់ខ្លួន។ ក្នុងករណី សមាគម និង អង្គការមិនមែនរដ្ឋាភិបាលបរទេស (ដូចអ្វីដែលបានរៀបរាប់ខាងលើ) គឺគ្មាននីតិវិធីក្នុងការតវ៉ាក្នុងកាលៈទេសៈបែបនេះឡើយ។ ក្នុងករណីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ប្រសិនបើ និង ពេលដែលការតវ៉ាប្រព្រឹត្តទៅតាមផ្លូវតុលាការ នោះគឺមិនមានភាពច្បាស់លាស់លើមូលដ្ឋានដែលតុលាការនឹងត្រូវធ្វើជាសំអាងក្នុងការសម្រេចសេចក្តីរបស់ខ្លួនថាតើការបដិសេធចុះបញ្ជីនោះស្របច្បាប់ ឬ មិនស្របច្បាប់។ ម.ស.ម.ក ធ្វើការតស៊ូមតិសុំឲ្យមានលក្ខខណ្ឌច្បាស់លាស់ក្នុងបដិសេធនេះ ឧ. ប្រើការត្រួតពិនិត្យដែលមានបីដំណាក់កាលដែលមានចែងក្នុង អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ សម្រាប់សេរីភាពសមាគម និងដូចអ្វីដែលបានពិភាក្សាទាក់ទងនឹងមាត្រា ១៧ ក្នុងផ្នែក១ខាងលើ។ តម្លាភាពត្រូវតែយកទៅអនុវត្តដោយស្របតាមការសម្រេចចិត្តគ្រប់លំដាប់ដែលនឹងត្រូវបានយល់ព្រមដោយការស្ថាបនាឡើងវិញនៃកាតព្វកិច្ចផ្តល់វិក័យប័ត្រថ្លៃចុះបញ្ជី។ លើសពីនេះទៀត គ្មានបទប្បញ្ញត្តិចែងអំពីថាតើគេត្រូវធ្វើដូចម្តេចក្នុងករណីដែលក្រសួងមហាផ្ទៃ ឬក្រសួងការបរទេសមិនបានដំណើរការចុះបញ្ជីក្នុងរយៈពេលកំណត់៤៥ថ្ងៃ។ គួរតែមានការបញ្ជាក់ឲ្យបានច្បាស់ថា នៅក្នុងកាលៈទេសៈបែបនេះ ការចុះបញ្ជីនឹងត្រូវធ្វើជាស្វ័យប្រវត្តិ បើមិនអញ្ចឹងទេអង្គការមិនមែនរដ្ឋាភិបាលនានានឹងត្រូវបានបុរេនិច្ឆ័យដោយអយុត្តិធម៌ ថ្វីគ្មានប្រសិទ្ធិភាពរបស់ក្រសួងក៏ដោយ។ ជាចុងបញ្ចប់នីតិវិធីនៃការចុះបញ្ជីគឺនៅតែជាទម្ងន់ដ៏ធ្ងន់មកលើអង្គការមិនមែនរដ្ឋាភិបាលតូចៗ ដែលមានធនធាន ឬសមត្ថភាពតិចតួច ដើម្បីដំណើរការនីតិវិធីចុះបញ្ជីដ៏វែងឆ្ងាយ ឬដើម្បីចុះបញ្ជីដែលលក្ខណៈប្រមូលផ្តុំ និង មានអំណះអំណាងដែលលើកឡើងថាគួរតែមានប្រព័ន្ធចុះបញ្ជីប្រកបដោយភាពងាយស្រួល ដែលឆ្លើយតបនឹងការបែងចែករវាងសមាគម/អង្គការមិនមែនរដ្ឋាភិបាលធំៗនៅថ្នាក់ជាតិ និង សមាគម/អង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់តូចនៅថ្នាក់ខេត្ត។

III. **ការលុបឈ្មោះចេញពីបញ្ជី/ការរំលាយៈ** សេចក្តីព្រាងលើក៤ ផ្តល់សមត្ថកិច្ចទូទៅដល់រដ្ឋាភិបាលកម្ពុជាដើម្បីលុបឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនចេញពីបញ្ជី ដោយទុកជាការដាក់ទណ្ឌកម្មចំពោះការរំលោភមួយចំនួន ដូចជាតាមមាត្រា១៧ មាត្រា៣០ និង ៣១ ដោយមិនមាននីតិវិធីក្នុងការតវ៉ា ។ ដោយសារគ្មានស្ថាប័នឯករាជ្យមួយដែលមានលក្ខណៈដូចតុលាការ ដូច្នេះការសម្រេចលើបញ្ហានេះត្រូវតែធ្វើឡើងតាមរយៈតុលាការជាជាងធ្វើឡើងតាមអង្គនីតិប្រតិបត្តិ ដើម្បីការពារចំពោះសេចក្តីសម្រេចចិត្តបែបនយោបាយនិងរដ្ឋបាល ហើយ

ជាមួយនឹងតុលាការដែលគោរពតាមលក្ខខណ្ឌដែលទទួលយកដោយអន្តរជាតិ។ ខណៈដែលផ្នែកទី២នៃមាត្រា២៨ទទួលស្គាល់ ទោះបីជាផ្នែកទីពីរនៃមាត្រា២៨ទទួលស្គាល់សមត្ថកិច្ចតុលាការក្នុងការសម្រេចចិត្ត បទប្បញ្ញត្តិនេះមិនស្របទៅនឹងផ្នែកផ្សេងទៀតរបស់សេចក្តីព្រាងច្បាប់។ ជាងនេះទៅទៀត មាត្រា១៨សំដៅទៅលើ (ដោយការភាន់ច្រឡំខ្លាំង) "ការរំលាយ" ជាជាងការ "លុបឈ្មោះចេញពីបញ្ជា" ដូច្នេះត្រូវតែធ្វើការកែប្រែដើម្បីឲ្យមានភាពច្បាស់លាស់និងភាពស្របគ្នា។ ចុងបញ្ចប់ក្រសួងមហាផ្ទៃត្រូវជូនដំណឹងដល់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធមុនពេលលុបឈ្មោះពួគេចេញពីបញ្ជី ដោយហេតុថាមានអង្គការមិនមែនរដ្ឋាភិបាលជាច្រើនជាពិសេសសមាគមនៅតំបន់ជនបទ មិនបានដឹងអំពីនីតិវិធីតម្រូវឲ្យតម្កល់សេចក្តីជូនដំណឹងនៅក្រសួងមហាផ្ទៃឡើយ។

### ៣. សេចក្តីសន្និដ្ឋាន

ម.ស.ម.ក សូមស្វាគមន៍ចំពោះការកែប្រែប្រសើរជាមុនទៅលើច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនេះ ជាពិសេសចំពោះភាពបញ្ជាក់ច្បាស់លាស់។ ផ្នែកទី១ខាងលើបង្ហាញថា អនុសាសន៍របស់សង្គមស៊ីវិលមួយចំនួនត្រូវបានពិចារណា និង កែតម្រូវតាម ដែលនេះគួរតែកោតសរសើរដល់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។ ជាលទ្ធផល សេចក្តីព្រាងច្បាប់លើកទី៤ មានចំនុចប្រសើរច្រើន ជាងសេចក្តីព្រាងច្បាប់ទាំងបីមុន។

ទោះជាយ៉ាងណាក៏ដោយ ផ្នែកទីពីរបង្ហាញថានៅមានចំណុចមួយចំនួនទៀតដែលនៅតែជាក្តីព្រួយបារម្ភដ៏ធំធេង។ ម.ស.ម.កជំរុញយ៉ាងមុតមាំដល់រាជរដ្ឋាភិបាលឲ្យបញ្ចូលនូវការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយនឹងសង្គមស៊ីវិល ដើម្បីជំរុញឲ្យការកែប្រែបញ្ចប់លើសេចក្តីព្រាងច្បាប់នេះនឹងកើតចេញជារូបរាងឡើង ជាមួយនឹងទស្សនៈមួយស្របតាមច្បាប់ដែលអាចប្រើប្រាស់ឲ្យមានប្រយោជន៍ក្នុងការអភិវឌ្ឍន៍សង្គមស៊ីវិលបន្ថែមទៀតនៅកម្ពុជា។ ម.ស.ម.ក ប្តេជ្ញាចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់នេះ និងផ្សាភ្ជាប់ទំនាក់ទំនងយ៉ាងពេញលេញជាមួយនឹងរាជរដ្ឋាភិបាល។

ទោះជាសេចក្តីព្រាងច្បាប់លើកទី៤នេះបានប្រសើរជាងយ៉ាងណា ហើយមានលក្ខណៈវិជ្ជមាននៅក្នុងសេចក្តីព្រាងច្បាប់លើកក្រោយយ៉ាងណានោះទេ បរិបទបើកឲ្យកាន់តែទូលាយគួរតែត្រូវបានរៀបចំឡើង។ នៅក្នុងសៀវភៅវិភាគសង្ខេបស្តីពីច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល[2] ចេញផ្សាយនៅខែតុលាឆ្នាំ២០១១ ម.ស.ម.ក បានលើកឡើងពីការគំរាមគំហែងដែលមាននៅក្នុងច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលចំពោះសង្គមស៊ីវិល និងកម្មវិធីម្ចាស់ជំនួយ។ ការគំរាមគំហែងនេះមិនទាន់បានបាត់ទៅវិញនៅឡើយទេ ប៉ុន្តែមានការកែប្រែដ៏គួរឲ្យកត់សម្គាល់នៅក្នុងច្បាប់នោះដោយផ្អែកលើភាពច្បាស់លាស់ និង ភាគច្រើនមានចំណុចកែប្រែគួរឲ្យស្វាគមន៍មួយចំនួន ជាពិសេសទាក់ទងនឹងបទប្បញ្ញត្តិដែលតម្រូវការដាច់ខាតក្នុងការចុះបញ្ជី ទោះជាយ៉ាងណាក៏ដោយ កំហុសឆ្គងនៅតែមាន នេះបបង្ហាញពីការថយចុះគួរឲ្យកត់សម្គាល់ក្នុងកំរិតគំរាមគំហែង។ ច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនៅតែមានកន្លែងចន្លោះប្រហោងដែលអាចបំពានបាន ជាពិសេសទៅលើសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលបរទេស ប៉ុន្តែ ម.ស.ម.ក

[2] http://www.cchrcambodia.org/index.php?url=media/media.php&p=analysis_detail.php&anid=16&id=5.

មានសុទិដ្ឋិនិយមយ៉ាងមុតមាំថា ការកែប្រែបន្ថែមទៀតដែលបានគូសបញ្ជាក់នៅក្នុងការវិភាគនេះ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ថ្មី ហើយថាលទ្ធផលនៃច្បាប់បទប្បញ្ញត្តិនេះនឹងពិតជាដើរតួជាចំនុចយោងដ៏ច្បាស់លាស់សម្រាប់សង្គមស៊ីវិលធ្វើការពាក់ព័ន្ធនឹងរាជរដ្ឋាភិបាល ដែលជាឧបករណ៍សម្រាប់ជួយសម្រួល "ឲ្យមានបរិយាកាស" ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមនៅកម្ពុជា ជាជាងការគំរាមគំហែងចំពោះសង្គមស៊ីវិល ដូចដែលបានភ័យខ្លាចកន្លងមក ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)
ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១១
រាជធានី ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា